01211960

E389

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 03 / 2016
ម៉ោង (Time/Heure): 16:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GIRAUD

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យអ្នកជំនាញធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសាស្ត្រទៅលើជនជាប់ចោទដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា នួន ជា និង ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ។

## ២. សំអាងហេតុ

២. អង្គជំនុំជម្រះសាលាដំបូង តាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចចាត់តាំងអ្នកជំនាញដើម្បីធ្វើការពិនិត្យវាយតម្លៃសម្បទាផ្នែករាងកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទ[1]។ កាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចចំនួនបួនទាក់ទងទៅនឹងការវាយតម្លៃសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងសេចក្តីសម្រេចចំនួនពីរទាក់ទងទៅនឹងការវាយតម្លៃសម្បទារបស់ ខៀវ សំផន ក្នុងការចូលរួមសវនាការ ដោយអង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានជារៀងរាល់លើកថា ជនជាប់ចោទនីមួយៗមានសមត្ថភាពពេញលេញក្នុងការចូលរួមក្នុងសំណុំរឿង០០២[2]។ សេចក្តីសម្រេចថ្មីៗ

---

[1] វិធាន ៣១, ៣២ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩។ សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣។

[2] សេចក្តីសម្រេចលើកទីបួន ទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E329/7 ("សេចក្តីសម្រេចលើកទីបួនលើសម្បទារបស់ នួន ជា") ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥។ សេចក្តីសម្រេចលើកទីពីរទៅលើកាយសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E329/8 ("សេចក្តីលើកទីពីរលើសម្បទារបស់ ខៀវ សំផន ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើកទីពីរ ទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E265/5 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣។ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារ E238/9 ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១។ សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Pavle Strugar* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបញ្ចប់កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សំណុំរឿងលេខ IT-01-42-T ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៥)។

បំផុតដែលបានចេញនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ផ្អែកទៅលើការពិនិត្យរបស់អ្នកជំនាញដែលបានធ្វើឡើងនៅក្នុងខែ មករា ឆ្នាំ ២០១៥[3] ដែលក្នុងអំឡុងពេលនៃការពិនិត្យនោះ អ្នកជំនាញពុំបានរកឃើញភ័ស្តុតាងណាមួយបង្ហាញថា ជនជាប់ចោទនីមួយៗមានការចុះខ្សោយផ្នែកបញ្ញាស្មារតី ឱ្យខុសពីធម្មតានៃបញ្ញាស្មារតីរបស់មនុស្សដែលមានអាយុ និងសាវតារ ដូចពួកគាត់នោះឡើយ[4]។ អ្នកជំនាញពុំបានផ្តល់អនុសាសន៍អ្វីឡើយនៅក្នុងរបាយការណ៍របស់ខ្លួន ពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តរបស់ នួន ជា ឬ ខៀវ សំផន[5]។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកជំនាញបានកត់សម្គាល់ថា ការចងចាំ និងមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទទាំងពីរ អាចនឹងមានការធ្លាក់ចុះជាបន្តទៀតទៅតាមអាយុរបស់ពួកគាត់ និងបានផ្តល់អនុសាសន៍ថា ជនជាប់ចោទទាំងពីរនាក់គួរតែមានការពិនិត្យមុខងារបញ្ញាស្មារតីជាទៀតទាត់[6]។

៣. នៅក្នុងសវនាការពិសេសថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អ្នកជំនាញបានផ្តល់សក្ខីកម្មថា ប្រការដែលមានទិន្នន័យបន្ថែមទៀតអំពីសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទ នឹងជួយបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការវាយតម្លៃសម្បទារបស់ជនជាប់ចោទ នៅក្នុងការពិនិត្យវាយតម្លៃនាពេលខាងមុខ[7]។ លើសពីនេះទៀត បន្ទាប់ពីមានការផ្អាកកិច្ចដំណើរការនីតិវិធីចំនួនបីលើកនៅក្នុងរយៈពេលពីរបីសប្តាហ៍ ដោយសារតែ ខៀវ សំផន ប្រឈមនឹងកម្រិតសម្ពាធឈាមខ្ពស់[8] អ្នកជំនាញបានផ្តល់អនុសាសន៍ឱ្យមានការកាត់បន្ថយពេលវេលានៃថ្ងៃសវនាការជាធម្មតារបស់អង្គជំនុំជម្រះ ដើម្បីអាចឱ្យជនជាប់ចោទមានពេលវេលាសម្រាកបានយូរជាងនេះ[9]។

---

[3] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ – នួន ជា ឯកសារ E329/4 ("របាយការណ៍អំពី នួន ជា") ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ – ខៀវ សំផន ("របាយការណ៍អំពី ខៀវ សំផន") ឯកសារ E329/5 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ជារួមហៅថា "របាយការណ៍"។

[4] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៤៤។ របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៤៣។

[5] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៣៨។ របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៣៨។

[6] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៤៦។ របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៤៥។

[7] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ (ភាសាអង់គ្លេស) ៤៣-៤៧ ។

[8] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ទំព័រ (ភាសាអង់គ្លេស) ៦២-៦៣ ។ ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ទំព័រ (ភាសាអង់គ្លេស) ៤៣-៤៧ ។ ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ទំព័រ (ភាសាអង់គ្លេស) ៨១ ។

[9] ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ (ភាសាអង់គ្លេស) ៣៥, ៤៨-៥៣។ សូមមើលផងដែរ អ៊ីមែលលើកទីមួយ ពី WESU ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ឆ្លើយតបទៅនឹងឯកសារ E329/6, E329/6/1 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ អ៊ីមែលដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទាជនជាប់ចោទក្នុងការចូលរួមសវនាការ/ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦/ សាធារណៈ

៤. អនុលោមតាមអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានកែសម្រួលកាលវិភាគសវនាការរបស់ខ្លួន ដើម្បីធ្វើសវនាការរយៈពេលពីរម៉ោងកន្លះនៅពេលព្រឹក និងពីរម៉ោងកន្លះនៅពេលរសៀល ដោយត្រូវឈប់សម្រាករយៈពេលពីរម៉ោងសម្រាប់អាហារថ្ងៃត្រង់[10]។ អង្គជំនុំជម្រះក៏បានបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីរបស់ជនជាប់ចោទទាំងពីររូប ប្រចាំត្រីមាសផងដែរ[11]។ អង្គភាពវេជ្ជសាស្ត្រ បន្តត្រួតពិនិត្យកម្រិតសម្ពាធឈាមរបស់ ខៀវ សំផន យ៉ាងហ្មត់ចត់ ជារៀងរាល់ថ្ងៃនៃកិច្ចដំណើរការនីតិវិធីតុលាការ។ ចាប់តាំងពីសវនាការពិសេសនោះមក នួន ជា និង ខៀវ សំផន មិនដែលត្រូវបានបញ្ជូនឱ្យចូលទៅសម្រាកនៅក្នុងមន្ទីរពេទ្យឡើយ ។ បច្ចុប្បន្ននេះ នួន ជា មានអាយុ ៨៩ ឆ្នាំ ហើយ ខៀវ សំផន មានអាយុ ៨៣ ឆ្នាំ[12]។ ដោយពិចារណាទៅលើភវនីយភាពដែលថា ការចងចាំ និងមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ នឹងមានការធ្លាក់ចុះទៅតាមអាយុ[13] តាមទិន្នន័យនាថ្មីៗស្តីពីមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ[14] និងរយៈពេលចាប់តាំងពីការពិនិត្យវាយតម្លៃនាពេលថ្មីៗកន្លងមកទៅលើសម្បទារបស់ជនជាប់ចោទរួចមក អង្គជំនុំជម្រះសាលាដំបូង

---

លលើកទីពីរពី WESU ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ឆ្លើយតបទៅនឹងឯកសារ E329/6, E329/6/2 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

[10] ប្រតិចារិក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ ទំព័រ (ភាសាអង់គ្លេស) ២៦។ សេចក្តីសម្រេចលើកទីបួនលើសម្បទារបស់ នួន ជា កថាខណ្ឌ ១៤។ សេចក្តីលើកទីពីរលើសម្បទារបស់ ខៀវ សំផន កថាខណ្ឌ ១២។

[11] ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស ឯកសារ E329/9 ថ្ងៃទី 0៩ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស - សេចក្តីបញ្ជាក់ ឯកសារ E329/9.1 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យកំណត់ពេលវេលានៃការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ ឯកសារ E329/11 ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥។ សូមមើល ផងដែរ ការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ឯកសារ E329/10 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥។

[12] សាលក្រមសំណុំរឿង 00២/0១ ឯកសារ E313 ថ្ងៃទី 0៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣០៥, ៣៥១។

[13] របាយការណ៍អំពី នួន ជា កថាខណ្ឌ ៤៦។ របាយការណ៍អំពី ខៀវ សំផន កថាខណ្ឌ ៤៥។

[14] ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ នួន ជា ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E10/273.1 ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦។ ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ ខៀវ សំផន ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E13/270.1 ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦។ ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ នួន ជា ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ E10/259.1 ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥។ ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ ខៀវ សំផន ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ E13/256.1 ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥។ ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ នួន ជា ខែសីហា ឆ្នាំ ២០១៥ ឯកសារ E10/247.1 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥។ ការធ្វើតេស្តត្រួសៗលើបញ្ញាស្មារតីរបស់ ខៀវ សំផន ខែ សីហា ឆ្នាំ ២០១៥ ឯកសារ E13/244.1 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥។

យល់ឃើញថា ជាការសមស្របក្នុងការពិនិត្យវាយតម្លៃឡើងវិញលើសម្បទារបស់ជនជាប់ចោទនៅពេលនេះ។

## ៣. ការចាត់តាំងអ្នកជំនាញ

៥. អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់តាំងវេជ្ជបណ្ឌិត Kin Ming CHAN ដែលមានជំនាញខាងព្យាបាលថែទាំមនុស្សចាស់ និងវេជ្ជបណ្ឌិត ហ្វួត លីនណា ដែលជំនាញផ្នែកវិកលវិទ្យា (“ជារួមហៅថា “អ្នកជំនាញ”) ដើម្បីវាយតម្លៃលើ នួន ជា និង ខៀវ សំផន និងត្រួតពិនិត្យសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងធ្វើសេចក្តីរាយការណ៍ជូនទៅអង្គជំនុំជម្រះសាលាដំបូងនូវលទ្ធផលនៃការពិនិត្យរបស់ពួកគាត់[15]។ ជាដំបូង អ្នកជំនាញម្នាក់ៗត្រូវធ្វើសម្បថដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងដោយភាពស្មោះត្រង់ ដោយសម្ងាត់ និងអស់ពីលទ្ធភាព[16]។ បន្ទាប់ពីធ្វើការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររួចមក អ្នកជំនាញត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សររួមគ្នាមួយស្តីអំពី លទ្ធផលនៃការពិនិត្យ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនចំពោះជនជាប់ចោទម្នាក់ៗ។ របាយការណ៍នីមួយៗ ត្រូវរួមបញ្ចូលនូវសេចក្តីបញ្ជាក់របស់អ្នកជំនាញថា អ្នកជំនាញ បានធ្វើការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និងបានធ្វើរបាយការណ៍ជារួម ឬ ជាបុគ្គល ។ អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យអ្នកជំនាញធ្វើការទំនាក់ទំនងជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន សម្រាប់គោលបំណងនេះ។

៦. របាយការណ៍របស់អ្នកជំនាញ ត្រូវរួមបញ្ចូលនូវព័ត៌មាន ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដែលបានពិពណ៌នានៅក្នុងរឿងក្តី *Strugar* ដែលនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើជនជាប់ចោទម្នាក់ៗមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ ។ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានានូវការចូលរួមនៅក្នុងដំណើរការសវនាការ ប្រកបដោយប្រសិទ្ធភាពរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន អ្នកជំនាញក៏ត្រូវធ្វើការវាយតម្លៃ និងធ្វើ

---

[15] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីមុនថា វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហ្វួត លីនណា គឺជាអ្នកជំនាញដែលមានគុណវុឌ្ឍិ និងបានចាត់តាំងពួកគាត់ឱ្យធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទ។ សូមមើល សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ ឯកសារ E301/10 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១០។

[16] វិធាន ៣១(២) នៃវិធានផ្ទៃក្នុង។

របាយការណ៍ផងដែរអំពីថាតើ ការសម្របសម្រួលដែលបានផ្តល់ជូន រួមទាំង ឧបករណ៍សោត-ទស្សន៍ និងការកំណត់រយៈពេលសម្រាប់ចូលរួមក្នុងសវនាការ ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងបញ្ហាសុខភាពជាក់ស្តែងរបស់ជនជាប់ចោទម្នាក់ៗដែរឬទេ។

៧. អនុលោមតាមភារកិច្ចនេះ អង្គជំនុំជម្រះសាលាដំបូង**បង្គាប់**ថា អ្នកជំនាញត្រូវ៖

(ក) ពិនិត្យនូវរាល់របាយការណ៍ជំនាញ និងរបាយការណ៍វេជ្ជសាស្ត្រដែលពាក់ព័ន្ធទាំងអស់ និងសម្ភារៈនានាដែលមាននៅក្នុងសំណុំរឿង ក្នុងពេលបច្ចុប្បន្ន និងសម្ភារៈនានាដែលត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អង្គភាពវេជ្ជសាស្ត្ររបស់ អ.វ.ត.ក និងមន្ទីរពេទ្យផ្សេងទៀត។

(ខ) ពិនិត្យជនជាប់ចោទម្នាក់ៗ ក្នុងគោលបំណង ដើម្បីកំណត់នូវកម្រិតសុខភាពផ្លូវកាយ និងបញ្ហាស្មារតីរបស់គាត់ ក៏ដូចជា ការវិនិច្ឆ័យទៅលើស្ថានភាពសុខភាព និងបញ្ហាស្មារតីរបស់ជនជាប់ចោទម្នាក់ៗ និងភាពល្អប្រសើរឡើង ឬ ភាពចុះដុនដាបនៃស្ថានភាពទាំងនេះ ចាប់តាំងពីមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងបញ្ហាស្មារតីរបស់ជនជាប់ចោទ កាលពីពេលថ្មីៗកន្លងទៅនេះ។

(គ) ធ្វើការពិគ្រោះយោបល់តាមការចាំបាច់ ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ និងអ្នកជំនាញជំងឺផ្លូវចិត្តផ្សេងទៀត ដែលបានធ្វើរបាយការណ៍ជូនការិយាល័យសហ-ចៅក្រមស៊ើបអង្កេតកាលពីលើកមុន អំពីស្ថានភាពរបស់ជនជាប់ចោទ ឬ ជាមួយវេជ្ជបណ្ឌិតដែលធ្លាប់បានព្យាបាលជំងឺរបស់ជនជាប់ចោទម្នាក់ៗ ឬ ពិនិត្យបញ្ហាផ្សេងទៀត ក្នុងអំឡុងពេលដែលពួកគាត់ស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក.។

(ឃ) បង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួនអំពីការវិនិច្ឆ័យណាមួយ និងការវិនិច្ឆ័យបន្ថែមទាំងអស់ ដែលត្រូវបានបង្គាប់ដោយអ្នកជំនាញ ប៉ុន្តែ ត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងទៀត រួមជាមួយនឹងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ។

(ង) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗ។

៨. អ្នកជំនាញត្រូវចាត់ទុកការងាររបស់ខ្លួនថាជាការសម្ងាត់ ដូចជា ការរក្សាការសម្ងាត់រវាងគ្រូពេទ្យ និងអ្នកជំងឺ ហើយនឹងមិនត្រូវលាតត្រដាងព័ត៌មានណាមួយ ស្ដីអំពីលទ្ធផលនៃការពិនិត្យ សេចក្ដីសន្និដ្ឋាន ឬ របាយការណ៍របស់ខ្លួនឡើយ លើកលែងតែការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ឬ ជូនអ្នកជំនាញដែលទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈពេទ្យផ្សេងទៀត នៅក្នុងអំឡុងពេលធ្វើការពិគ្រោះយោបល់ទាំងឡាយ ដែលបានយោងនៅក្នុងកថាខណ្ឌ ៧ (គ) *ខាងលើ* ។ អ្នកជំនាញត្រូវមានអ្នកបកប្រែភាសាដើម្បីជួយដល់ពួកគាត់ ព្រមទាំង ជំនួយការជនជាតិខ្មែរដែលបានទទួលការបណ្ដុះបណ្ដាលផ្នែកវិជ្ជាជីវៈពេទ្យ ហើយពួកគាត់ទាំងនោះ ក៏ត្រូវមានកាតព្វកិច្ចផងដែរ ដើម្បីគោរពនូវការសម្ងាត់នៃការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និងរបាយការណ៍។

៩. អ្នកជំនាញត្រូវប្រតិបត្តិតាមសេចក្ដីបង្គាប់ទាំងនេះ ហើយក្រៅពីនេះ អ្នកជំនាញត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយបទប្បញ្ញត្តិជាធរមានទាំងអស់នៃវិធាន ៣១ និងវិធាន ៣២ នៃវិធានផ្ទៃក្នុង។

១០. តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងផ្នែកគ្រប់គ្រងតុលាការ អង្គជំនុំជម្រះសាលាដំបូងនឹងផ្ដល់ជូនអ្នកជំនាញនូវរាល់ឯកសារសម្ងាត់ទាំងអស់ពាក់ព័ន្ធផ្នែកវេជ្ជសាស្ត្រ ដែលមាននៅក្នុងសំណុំរឿង នាពេលបច្ចុប្បន្ននេះ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវសម្របសម្រួលឱ្យមានអ្នកបកប្រែភាសាដើម្បីជួយដល់អ្នកជំនាញ នៅក្នុងអំឡុងពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់។

១១. អ្នកបកប្រែភាសា បុគ្គលិកពេទ្យ និងអ្នកផ្សេងទៀតទាំងអស់ដែលជួយដល់អ្នកជំនាញ ឬ ជួយសម្រួលដល់ការពិនិត្យផ្នែកវេជ្ជសាស្ត្ររបស់ពួកគាត់ ទៅលើជនជាប់ចោទ ត្រូវគោរព និងប្រតិបត្តិតាមដីកានេះ និងភាពសម្ងាត់នៃការពិនិត្យផ្នែកវេជ្ជសាស្ត្រ លទ្ធផលនៃការពិនិត្យ និងរបាយការណ៍របស់អ្នកជំនាញ។

**ផ្អែកទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**ចាត់តាំង** វេជ្ជបណ្ឌិត Kin Ming CHAN និងវេជ្ជបណ្ឌិត ហួត លីនណា ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទ នួន ជា និង ខៀវ សំផន អនុលោមតាមដីកានេះ។

**ជូនដំណឹង** ដល់គ្រប់ភាគីថា ការពិនិត្យជនជាប់ចោទផ្នែកវេជ្ជសាស្ត្រ នឹងត្រូវចាប់ផ្តើមពីថ្ងៃទី ២៥ ដល់ថ្ងៃ ២៦ ខែ  កក្កដា ឆ្នាំ ២០១៦ ហើយរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់ជនជាប់ចោទម្នាក់ៗជាភាសាអង់គ្លេស នឹងត្រូវបញ្ចប់ជាស្ថាពរនៅត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ។ សំណៅបកប្រែជាភាសាផ្លូវការនៃរបាយការណ៍នីមួយៗដែលពាក់ព័ន្ធនោះ      នឹងត្រូវផ្តល់ទៅឱ្យមេធាវីជនជាប់ចោទ នៅត្រឹមថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦។

**កត់សម្គាល់**ថា ប្រសិនបើមានការតម្រូវពីអង្គជំនុំជម្រះនោះ អ្នកជំនាញនឹងធ្វើការបង្ហាញលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្ររបស់ខ្លួន និងឆ្លើយតបទៅនឹងសំណួររបស់ភាគីនានា នៅក្នុងសវនាការដែលត្រូវធ្វើឡើងនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦។ និង

**ស្នើសុំ**ឱ្យការិយាល័យរដ្ឋបាលរបស់  អ.វ.ត.ក.  និងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត  ផ្តល់នូវជំនួយចាំបាច់ទាំងអស់ដល់អ្នកជំនាញសម្រាប់រយៈពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**